# ទស្សនទានស្តីពីត្រពាំង និងការគ្រប់គ្រងទឹកកសាងអង្គរ


បណ្ឌិត **ឈឿន ប៊ុនឆា**

មន្ត្រីជំនួយការបណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន** សមាជិកស្ថាបនិក

នៃរាជបណ្ឌិត្យសភាកម្ពុជា


## សេចក្តីផ្តើម

*ភូមិសាស្ត្រប្រទេសកម្ពុជាមានផ្ទៃផតកណ្តាល រាងដូចបាតខ្ទះ ដែលព័ទ្ធស្ទើរជុំវិញទៅដោយភ្នំនិងខ្ពង់រាប[១]។ ដោយសណ្ឋានដីមានលក្ខណៈបែបនេះធ្វើឱ្យប្រទេសកម្ពុជាសំបូរទៅដោយស្ទឹង ព្រែក បឹង និងទន្លេ ជាពិសេសត្រពាំងសុទ្ធសឹងមានស្ទើរគ្រប់ភូមិ ឃុំ ស្រុកទូទាំងប្រទេស។*

*ត្រពាំង ជាថ្លុកធំកើតពីមនុស្សជីកសម្រាប់ឱ្យដក់ទឹក ឬកើតដោយសារកម្លាំងទឹកហូរច្រោះក៏មាន។ម្យ៉ាងទៀត ត្រពាំងជាទីដក់ទឹកធំដូចគ្នានឹងស្រះដែរ ប៉ុន្តែត្រពាំងកើតឡើងឯងពីធម្មជាតិផងដែរ ដែលភាគច្រើនត្រពាំងស្ថិតនៅទីខ្ពស់ជាងទំនាបបឹង តាមវាលនិងក្នុងព្រៃ។ ជាមួយគ្នានេះ ត្រពាំងជាសម្បត្តិសមូហភាព បានស្តុកទឹកទុកទាំងរដូវវស្សានិងរដូវប្រាំង ជាហេតុធ្វើឱ្យត្រពាំងអាចផ្តល់ទឹកសម្រាប់ស្រោចស្រពដំណាំ និងជាប្រភពទឹកដ៏សំខាន់សម្រាប់មនុស្សសត្វ រុក្ខជាតិ និងជីវចំរុះ[២]។*

*តួយ៉ាង ស្ទើរនៅគ្រប់តំបន់ប្រាសាទបុរាណខ្មែរ សុទ្ធសឹងមានស្រះ ត្រពាំង កញ្ចន់ គូទឹក និងកសិន្ធប្រាសាទជាដើម។*

*ដោយសារពុំមានការស្តារ និងសកម្មភាពរបស់មនុស្សជាយូរឆ្នាំ ត្រពាំងភាគច្រើនត្រូវបានគោករាក់ស្មើវាលស្រែ ដែលបណ្តាលឱ្យត្រពាំងរីងស្ងួត ហួតហែង កង្វះទឹកនារដូវប្រាំង។ ការស្តារនិងអភិរក្សត្រពាំង ពិតជានឹងចូលរួមចំណែកជួយផ្តល់ប្រភពទឹក រក្សាពូជត្រីនិងជីវចំរុះ ព្រមទាំងផ្តល់នូវប្រភពទឹក*

---

[១] *ភូមិសាស្ត្រប្រទេសកម្ពុជា គ្រឹះស្ថានបោះពុម្ព-បណ្ណាគារអង្គរ ភ្នំពេញ គ.ស.២០១៥។*

[២] https://choukhmer.wordpress.com/2010/11/28/terminology-of-water-system-in-khmer-language/

*សម្រាប់ស្រោចស្រពដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋមូលដ្ឋានផងដែរ។*

*ដោយមើលឃើញអត្ថប្រយោជន៍ និងបញ្ហាប្រឈមយ៉ាងដូច្នេះ ទើបមានប្រធានបទមួយ លើកឡើងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវឈ្វេងយល់អំពីត្រពាំងក្នុងប្រទេសកម្ពុជា។*

## ១. និយមន័យត្រពាំង

### ១.១. អ្វីទៅជាត្រពាំង?

*ពាក្យ "**ត្រពាំង**" សំដៅទីដក់ទឹកធំដូចគ្នានឹងស្រះដែរ ប៉ុន្តែត្រពាំងកើតឡើងឯងពីធម្មជាតិ ហើយត្រពាំងភាគច្រើនស្ថិតនៅទីខ្ពស់ជាងទំនាបបឹង តាមវាល និងក្នុងព្រៃក៏មាន។ រីឯ "**ស្រះ**" សំដៅទីដក់ទឹកធំ តែតូចជាងបឹង កើតឡើងពីការជីករបស់មនុស្ស ដើម្បីរក្សាទឹកទុកប្រើប្រាស់។ ស្រះភាគច្រើនស្ថិតនៅក្នុងភូមិ និងជាប់នឹងផ្ទះប្រជាពលរដ្ឋ (ខាងមុខ ខាងក្រោយ និងចំហៀងផ្ទះ)។ ចំណែក "**បឹង**" សំដៅថ្នក់ល្ហាលទឹកធំល្វឹងល្វើយ កើតឡើងពីធម្មជាតិ (ដោយបំណាក់ស្រុត ឬបន្ទុះភ្នំភ្លើង)។ បឹងភាគច្រើនស្ថិតនៅទីទំនាប តាមវាល ក្នុងព្រៃ និងនៅជាប់ភូមិម្តុំអ្នកស្រុក។*[៣]

*នៅប្រទេសកម្ពុជា គេសង្កេតឃើញមានត្រពាំងជាច្រើនស្ទើតែគ្រប់ភូមិ ឃុំ ស្រុកនៃបណ្តាខេត្តនីមួយៗទូទាំងប្រទេស។ ភូមិខ្លះមានត្រពាំងមួយកន្លែង ខ្លះទៀតមានត្រពាំងរហូតដល់ទៅពីរ ឬបួនកន្លែងឯណោះ។ "**ត្រពាំង**" គឺជាសម្បត្តិសាធារណៈ ដែលគ្មានបុគ្គលណាមួយអាចយកទៅធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនបានឡើយ។ វាត្រូវស្ថិតក្រោមការគ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋានផ្ទាល់សម្រាប់ជាសាធារណៈប្រយោជន៍។*

### ១.២. អំពីត្រពាំង

*ត្រពាំង មិនត្រឹមជាកន្លែងសម្រាប់ផ្ទុកទឹកនោះទេ។ ត្រពាំងត្រូវបានគេប្រើប្រាស់សម្រាប់សម្គាល់ទីកន្លែង ឈ្មោះភូមិ ឃុំ ស្រុក ខេត្តក៏មាន។ ឧទាហរណ៍ដូចជា "**ត្រពាំងសេះ**" នៅអង្គរវត្ត។ "**ភូមិត្រពាំងប្រាសាទ**" នៅឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ "**ឃុំត្រពាំងសង្កែ**" នៅស្រុកទឹកឈូ ខេត្តកំពត។ និង "**ខេត្តស្រះត្រពាំង**" ប្រទេសវៀតណាមសព្វថ្ងៃ។*

[៣] https://choukhmer.wordpress.com/2010/11/28/terminology-of-water-system-in-khmer-language/

## ២. ប្រវត្តិនៃការកកើតត្រពាំង

### ២.១. លក្ខណៈពិសេសនៃត្រពាំង

ប្រជាជនកម្ពុជាតែងរស់នៅប្រមូលផ្តុំគ្នាពីភូមិមួយទៅភូមិមួយ និងសហគមន៍មួយទៅសហគមន៍មួយទៀត។ ភូមិនីមួយៗសុទ្ធសឹងមានត្រពាំងដែលកើតឡើងពីធម្មជាតិ ឬដោយសារមនុស្សជីកក៏មាន។ ត្រពាំងភាគច្រើនស្ថិតនៅជិតភូមិឬរបស់អ្នកស្រុក ដែលជាទីផ្ទុកទឹកភ្លៀង និងពេលរដូវវស្សាជនលិចបានរក្សាទឹកទុកនៅរដូវប្រាំងដែលជាប្រភពទឹកដ៏មានអត្ថប្រយោជន៍សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ ជាពិសេស ត្រពាំងជាប្រភពទឹកដ៏សំខាន់ដល់ សត្វ គោ ក្របី ជ្រូក មាន់ ទា របស់ប្រជាពលរដ្ឋ។ មិនថានៅតាមភូមិឬរ ត្រពាំងក៏មាននៅតាមតំបន់ប្រាសាទបុរាណនានា ដែលបុព្វបុរសខ្មែរបានកសាង ដើម្បីទ្រទ្រង់ទីទួលប្រាសាទឱ្យបិតបេរគង់វង្សយូរអង្វែង។

### ២.២. អត្ថប្រយោជន៍នៃត្រពាំង

ត្រពាំងមិនត្រឹមជាទីផ្ទុក និងរក្សាទឹកនោះទេ ប៉ុន្តែត្រពាំងបានក្លាយជានិមិត្តរូបនៃការសាមគ្គីពីភូមិមួយទៅភូមិមួយទៀត និងពីសហគមន៍មួយទៅសហគមន៍មួយទៀត ដោយត្រពាំងជាសម្បត្តិសមូហភាពដែលបានផ្តល់នូវ៖

- ប្រភពទឹកសម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ។
- ការជួយថែរក្សាត្រី ក្តាម ខ្យងឱ្យមានការកើនឡើង។
- ជម្រកជីវចំរុះនានាដែលរស់នៅក្នុងទឹក។
- ការស្រោចស្រពវិស័យកសិកម្មនៅរដូវប្រាំង។
- ការប្រើប្រាស់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋមូលដ្ឋានដូចជាការដាំដុះបន្លែបង្ការ និងដំណាំរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងសហគមន៍។

លើសពីនេះ ត្រពាំងមិនត្រឹមជាប្រភពទឹកដ៏សំខាន់ ត្រពាំងជាសម្បត្តិរួមរបស់ប្រជាជនក្នុងការជួយអភិវឌ្ឍសេដ្ឋកិច្ចសង្គមឱ្យកាន់តែល្អប្រសើរថែមផង។

### ២.៣. ការចាំបាច់ត្រូវការស្តារ និងអភិរក្សត្រពាំង

ពីមួយឆ្នាំទៅមួយឆ្នាំ ដោយកង្វះការថែទាំ និងការរំលោភបំពានពីអាជ្ញាធរ

ក៏ដូចជាប្រជាពលរដ្ឋ បានបង្ករឱ្យត្រពាំងត្រូវបានគោករាក់ យូរៗទៅត្រពាំងខ្លះបានក្លាយជាវាលស្រែ រហូតមើលលែងស្គាល់ថាជាត្រពាំងទៀតផង។

ដោយសារត្រពាំងមានគុណប្រយោជន៍យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រុក្ខជាតិ និងសត្វ។ ដូច្នេះហើយ ការស្តារនិងអភិវឌ្ឍត្រពាំងឡើងវិញ ជាការចាំបាច់ដែលអាជ្ញាធរមូលដ្ឋាន ក៏ដូចជារាជរដ្ឋាភិបាល ត្រូវយកចិត្តទុកដាក់ក្នុងការអភិរក្ស និងអភិវឌ្ឍន៍ត្រពាំងដែលជាសម្បត្តិធនធានមានស្រាប់។

## ៣. ទស្សនៈស្តីពីការគ្រប់គ្រង

### ៣.១. សញ្ញាណទូទៅនៃការគ្រប់គ្រង

ការគ្រប់គ្រង គឺសំដៅដល់ការការគ្រប់គ្រងអង្គភាពមួយមិនថាតែជាអង្គភាពអាជីវកម្មឯកជនរកប្រាក់ចំណេញ ឬ មិនរកប្រាក់ចំណេញ ឬ អង្គភាពរដ្ឋជាស្ថាប័នចំណុះឱ្យរដ្ឋាភិបាលនោះទេ។ ការគ្រប់គ្រងរាប់បញ្ចូលទាំងសកម្មភាពនៃការបង្កើតយុទ្ធសាស្ត្ររបស់អង្គភាពមួយនិងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិក(ឬអ្នកស្ម័គ្រចិត្ត)ដើម្បីសម្របសម្រួលសម្រេចគោលបំណងរបស់ខ្លួនតាមរយៈការប្រើប្រាស់នូវធនធានដែលមានដូចជា៖ ធនធានហិរញ្ញវត្ថុ ធម្មជាតិ បច្ចេកវិទ្យា និងធនធានមនុស្សជាដើម[៦]។

ការងារគ្រប់គ្រង គឺជាការងារដ៏ពិបាកនឹងពិពណ៌នាមួយ ហើយការពិពណ៌នាអំពីការងារ នេះវារមែងមានភាពខុសគ្នា។ ការប្រកួតប្រជែងភាគច្រើនសម្រាប់អ្នកគ្រប់គ្រង គឺបំណែងចែកការរងារនិងភាពប្រែប្រួល ផ្លាស់ប្តូរចម្រុងចម្រើនទៅមុខជានិច្ចនៃការងារទោះជាក្នុងថ្ងៃជាមួយគ្នាក្តី។ ការធ្វើផែនការអាចមានការលំបាកពីការរំខានទាំងឡាយទាំងពួងហើយវាក៏អាចមានការលំបាកថែមទៀតក្នុងការអនុវត្តដែលយើងត្រូវធ្វើ។ លើសពីនេះទៅទៀត ប្រសិនបើអ្នកគ្រប់គ្រងជាប្រភេទមនុស្ស "ចិត្តក្តៅ" និងជាមនុស្សដែលនិយមចូល

[៦] H. Koontz, H. Weihrich, and Ramachandra Aryasri A., ***Principles of Management,*** 1st Edition, Tata McGraw-Hill Publishing Company Ltd., 2006.

ចិត្តដោះស្រាយបញ្ហារបៀបកំហឹងទល់កំហល់ និងមិនគិតមុខគិតក្រោយនោះ ការដោះស្រាយបញ្ហាការងារទាំងឡាយទាំងពួងមិនត្រឹមតែមិនបានផលទេផ្ទុយទៅវិញវារឹតតែបន្ថែមបញ្ហាថែមទៀតផង[៥]។ មិនតែប៉ុណ្ណោះ អ្នកគ្រប់គ្រងត្រូវមានសុភវិនិច្ឆ័យឱ្យបានត្រឹមត្រូវ ឈ្វេងយល់ទាំង៨ទិស ត្រង់នេះមានន័យថា អ្នកគ្រប់គ្រងក្តីឬអ្នកដឹកនាំក្តី ការសម្រេចចិត្តលើអ្វីមួយត្រូវសិក្សាស្វែងយល់ឱ្យបានសព្វគ្រប់ជ្រុងជ្រោយ ដើម្បីជៀសវាងការទទួលបានលទ្ធផលអវិជ្ជមានឬធ្វើការសម្រេចចិត្តមិនត្រឹមត្រូវ ដែលជាហេតុប៉ះពាល់ដល់ប្រយោជន៍អង្គភាព។

ជារួម ការគ្រប់គ្រងឬការចាត់ចែង គឺជាដំណើរការដែលសម្រេចគោលដៅជាក់លាក់របស់អង្គភាពមួយ និងអ្នកដឹកនាំឬនាំកម្លាំងមនុស្សដទៃ ដើម្បីសម្រេចសកម្មភាពដែលចាំបាច់ និងគោលដៅទាំងឡាយ។

### ៣.២. អត្ថន័យនៃពាក្យ "គ្រប់គ្រង"

តាមវចនានុក្រមខ្មែរ សម្តេចសង្ឃរាជ **ជួន ណាត** លោកបានពន្យល់ថា "**គ្របគ្រងឬ គ្រប់គ្រង**" មានន័យថា បីបាច់រក្សាថែទាំដោយទទួលរងបន្ទុករងខុសត្រូវលើខ្លួន[៦]។ ម្យ៉ាងទៀត គ្រប់គ្រងគឺសំដៅទៅរកការដឹកនាំមនុស្សឱ្យសម្រេចនូវរាល់ការងារទាំងឡាយក្នុងអង្គភាពទទួលខុសត្រូវចាត់ចែង និង ដំណើរការរបស់ខ្លួន ក៏ដូចជាការប្រើប្រាស់ធនធានមួយចំនួនដើម្បីសម្រេចគោលបំណងរបស់អង្គភាព[៧]។ បានន័យថាក្នុងនាមជាអ្នកគ្រប់គ្រងគេ ត្រូវទទួលខុសត្រូវ ថែរក្សាអ្នកនៅក្រោមបង្គាប់ឱ្យបានល្អ ត្រូវហ៊ានទទួលខុសត្រូវនូវរាល់ទង្វើបុគ្គលិកក្រោមបង្គាប់បានធ្វើ ដែលយើងអាចធ្វើការប្រៀបធៀបអ្នកគ្រប់គ្រងដូចជាឪពុកម្តាយថែទាំកូនឱ្យក្លាយជាកូនល្អរស់នៅក្នុងសង្គមដែលគេគ្រប់គ្នាឱ្យតម្លៃ ទោះបីជាកូនធ្វើខុសឪពុកម្តាយត្រូវហ៊ានចេញមុខទទួលខុសត្រូវ។ បើយើងគិតពិចារណាឱ្យស៊ីជម្រៅជាងនេះ យើងឃើញថាអ្នកគ្រប់គ្រងគឺជាអ្នកដែលមានឯកទេស និង ជំនាញប៉ិនប្រសប់នៅក្នុង

[៥] QUIN Susan, ***Management Basics***, 1st Edition, published 2010, page 11.

[៦] ជួន ណាត ***វចនានុក្រមខ្មែរភាគទី១*** ពុទ្ធសាសនបណ្ឌិត បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧ ទំព័រ១៥០។

[៧] សៅ ឡាយ ***សេចក្តីផ្តើមរដ្ឋបាលសាធារណៈ*** ឆ្នាំ២០០៨ ទំព័រ៥។

*ការធ្វើសេចក្តីសម្រេចចិត្តនិងទទួលខុសត្រូវចំពោះជោគជ័យរបស់អង្គភាពព្រោះយើងបានដឹងជាទូទៅថាអង្គភាពមួយទទួលបានជោគជ័យ និងមិនជោគជ័យអាស្រ័យលើការកាច់ចង្កូតរបស់អ្នកគ្រប់គ្រងដែលមានទំនួលខុសត្រូវខ្ពស់ទៅលើការងាររបស់ខ្លួន។ ជាទូទៅការងារគ្រប់គ្រង គឺកើតចេញមកពីការរៀនសូត្រ និង បទពិសោធន៍ដែលមានកន្លងមក ព្រោះគ្មានបុគ្គលណាម្នាក់ដែលធ្វើអ្វីមួយដែលមិនចេះខុសនោះទេ ប៉ុន្តែនៅពេលដែលយើងធ្វើខុសយើងត្រូវយកកំហុសនោះមកសិក្សារៀនសូត្រទុកជាមេរៀនសម្រាប់ជីវិតរបស់ខ្លួន។ ចំពោះសិល្បៈនៃការគ្រប់គ្រងទាមទារឱ្យអ្នកគ្រប់គ្រងមានជំនាញច្រើន ហើយត្រូវដឹងថាជំនាញណាគប្បីយកមកប្រើក្នុងកាលៈទេសៈសមស្របណាមួយ អ្នកគ្រប់គ្រងត្រូវស្វែងយល់ពីស្ថានភាពក្នុងក្រៅ និងបរិយាកាសនៅជុំវិញអង្គភាពឬស្ថាប័ននោះ ព្រមទាំងមានវិធី និងបច្ចេកទេសដើម្បីឆ្លើយតបទៅនឹងស្ថាន-ភាពទាំងនោះនឹងទៅតាមពេលវេលាសមស្របទៀតផង[៨]។ ការងារគ្រប់គ្រងអង្គភាព ឬស្ថាប័នឱ្យមានដំណើរការល្អអ្នកគ្រប់គ្រងត្រូវប្រាកដខ្លួនថាបានប្រើប្រាស់បុគ្គលិក និងប្រភពធនធានផ្សេងៗទៀតនៅក្នុងអង្គភាពរបស់ខ្លួនតាមរបៀបត្រឹមត្រូវមានប្រសិទ្ធភាព និងប្រកបដោយភាពសន្សំសំចៃឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅអង្គភាព។ អ្នកគ្រប់គ្រងត្រូវដឹកនាំអង្គភាពដោយភាពឈ្លាសវៃ និងភាពបត់បែនក្នុងការដោះស្រាយបញ្ហាដោយភាពទទួលខុសត្រូវ[៩]។*

*ការគ្រប់គ្រង គឺជាដំណើរការសម្រេចបាននូវលទ្ធផលតាមរយៈអ្នកដទៃ[១០]។ ការគ្រប់គ្រង វាមិនអាស្រ័យលើអ្នកគ្រប់គ្រងតែម្នាក់ឯងនោះទេ អ្នកគ្រប់គ្រងគ្រាន់តែជាអ្នកនាំគេធ្វើតែប៉ុណ្ណោះ ប៉ុន្តែអ្នកដទៃទេ ដែលជាបុគ្គលិកនៅក្រោមបង្គាប់របស់អ្នកគ្រប់គ្រងជាអ្នកធ្វើការងារឱ្យបានសម្រេចលទ្ធផលជូនអ្នកគ្រប់គ្រង និងអង្គភាពឬស្ថាប័ននោះឯង។ ម្យ៉ាងវិញទៀតការគ្រប់គ្រងគឺសំដៅទៅលើមនុស្ស*

[៨] ក្រសួងអប់រំយុវជន និងកីឡា ***ការងារគ្រប់គ្រងនិងរដ្ឋបាល*** ភ្នំពេញ ឆ្នាំ២០០៩ ទំព័រ១១។

[៩] សឿន សោភ័ណ ***ការងារគ្រប់គ្រងរដ្ឋបាលសាធារណៈ*** ឆ្នាំ ២០០៩-២០១០។

[១០] Mary Parkerm, ***the Six Strategy of Public Administration***, 1st Edition, 2004 page 201.

ដែលទទួលខុសត្រូវសម្រាប់ដំណើការអង្គភាព និងអភិក្រមសម្រាប់ដំណើរការអង្គភាពនោះតែម្តង ដោយប្រើប្រាស់នូវធនធានដើម្បីសម្រេចបានគោលបំណងរបស់អង្គភាព[១១]។ ក្នុងនាមជាអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវចំពោះអង្គភាពខ្លួនឱ្យមាន ដំណើរការទៅមុខ និងមានច្បាប់សម្រាប់ឱ្យអង្គភាពអនុវត្តឱ្យខ្ជាប់ខ្ជួន ហើយត្រូវចេះប្រើប្រាស់ ធនធានឱ្យត្រូវនឹងស្ថានភាពរបស់អង្គភាពដើម្បីឱ្យការអនុវត្តការងាររបស់អង្គភាពសម្រេចតាមផែនការបានគ្រោងទុក។ ការងារគ្រប់គ្រងត្រូវបានមើលឃើញមានលក្ខណៈវិទ្យាសាស្រ្ត ឬសិល្បៈ[១២]។ អ្នកគ្រប់គ្រងដែលមានលក្ខណៈវិទ្យាសាស្រ្តត្រូវអនុវត្តនូវយន្តការនៃការគ្រប់គ្រង ច្បាស់លាស់ រៀបចំផែនការ បទបញ្ជា សម្របសម្រួលត្រឹមត្រូវដោយប្រសិទ្ធភាពខ្ពស់ចំពោះការងារ ហើយការគ្រប់គ្រងមានលក្ខណៈជាសិល្បៈ បានន័យថាអ្នកគ្រប់គ្រងទទួលបានភាពជោគជ័យអាស្រ័យលើលក្ខណៈដូចជា ចេះអង្កេតសម្បទាន ការសម្រេចចិត្តច្បាស់លាស់ដោយបាន បង្កបរិយាកាសរីករាយនៅក្នុងអង្គភាព លើកកម្ពស់សេចក្តីថ្លៃថ្នូរដល់បុគ្គលិកទាំងអស់ជាមនុស្ស ដែលមានឥទ្ធិពលទាំងក្នុងនិងក្រៅអង្គភាព មានជំនឿជឿជាក់លើខ្លួនឯង។ ម្យ៉ាងវិញទៀត អ្នកគ្រប់គ្រងត្រូវមានភាពទន់ភ្លន់ និង ចេះបត់បែនតាមកាលៈទេសៈនៃការគ្រប់គ្រង។

## ៤. ការគ្រប់គ្រងទឹកកសាងអង្គរ

### ៤.១. សក្តានុពលនៃទឹក

សម័យអង្គរត្រូវបានប្រវត្តិវិទូខ្មែរ និងបរទេសកំណត់រយៈពេលចន្លោះ ពី ស.វទី៩ដល់ស.វទី១៥។ មូលដ្ឋានគ្រឹះមួយក្នុងចំណោមមូលហេតុ ជាច្រើន ដែលធ្វើឱ្យសម័យអង្គររុងរឿងដល់កំពូល រហូតដល់មានអរិយធម៌ ល្បីរន្ទឺលាតសន្ធឹងឆ្ងាយជាព្រំដែននៃអាណាចក្ររបស់ខ្លួនឯងទៅទៀតនោះ គឺការគ្រប់គ្រងទឹក។ មហាក្សត្រសម័យអង្គរសុទ្ធតែបានផ្តល់សារៈសំខាន់ ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធប្រមូលទឹកដើម្បី[១៣]៖ ១)ទ្រទ្រង់ និងពង្រីកវិស័យកសិកម្ម។ ២)បំពេញតម្រូវការប្រើប្រាស់

[១១] Shafriz, Jai M, and Rousell E W, ***International Public Administration, and Imprint of Addison Wesley Longman Inc.***, 1997 Page 97.

[១២] ***Human Resources Management***, J. Coyle-Shapiro, K. Hoque, I. Kessler, A. Pepper, R. Richardson, and L. Walker MN3075, 2013.

[១៣] វីដេអូឯកសារៈ ទឹកសាងអង្គរ https://fb.watch/fWK7FYiBXq/។

ប្រចាំថ្ងៃរបស់ប្រជារាស្ត្រ និង៣) ទ្រទ្រង់ដល់ប្រាសាទជាទីសក្ការៈ។ ការជ្រើសរើសសៀមរាបដើម្បី តាំងជារាជធានីនៅក្នុងសម័យអង្គរ មិនមែនជាការជ្រើសរើសដោយគ្មាន ការគិតគូរពិចារណាមុននោះឡើយ។ ព្រះមហាក្សត្រសម័យនោះបានស្គាល់ យ៉ាងប្រត្យក្សអំពីលក្ខណៈភូមិសាស្ត្រអំណោយផល ដែលស្ថិតនៅចន្លោះនៅ រវាងភ្នំគូលេនដែលជាប្រភពទឹក និងតំបន់ទំនាបដីល្បាប់នៃបឹងទន្លេសាប។ ស្ទឹង រលួសនេះមួយ ព្រែកជីកសៀមរាបនេះពីរ ស្ទឹងពួកនេះបី ដែលចេញពីភ្នំគូលេន ចុះមកបឹងទន្លេសាបបានផ្តល់គ្រឹះយ៉ាងសំខាន់មួយនៃភាពរឹងមាំរបស់អង្គរ នោះគឺទឹក។

## ៤.២. ការអភិវឌ្ឍប្រព័ន្ធទឹក

ទឹកគឺជាប្រភពចម្បងមួយក្នុងការកសាងសម័យអង្គរ ព្រះមហាក្សត្រសម័យអង្គរបានប្រើប្រាស់បារាយណ៍ជាយន្តការប្រមូលទឹកទុក។ ពាក្យថាបារាយណ៍គឺមិនមែនជាការជីកកាយលុងដីដូចធ្វើស្រះទឹកនោះឡើយ បារាយណ៍ជាការលើកទំនប់ព័ទ្ធជុំវិញ ដើម្បីស្តុកទឹករហូតដល់សព្វថ្ងៃនេះ ទាំងបារាយណ៍និងទឹកក៏នៅតែទ្រទ្រង់តំបន់អង្គរ។ ឆ្នាំ៨០២នៃគ្រិស្តសករាជជាឆ្នាំដំបូងនៃសម័យអង្គរ ជាឆ្នាំនៃការយាងឡើងគ្រងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី២[១៤]។ ព្រះបាទជ័យវរ្ម័នទី២ បន្ទាប់ពីបានប្រមូលកម្លាំងខ្មែរ ដែលនៅបែកគ្នានៅជានគរតូចៗឱ្យមករួមរស់ជាមួយគ្នាជាធ្លុងមួយហើយនោះ បានគង់នៅរាជធានីហរៈហរិល័យ ដែលត្រូវបានស្គាល់ថាជាតំបន់រលួសសព្វថ្ងៃនេះ។ បន្ទាប់មកព្រះអង្គក៏យាងឡើងគង់នៅភ្នំគូលែននិងបានសាងសង់សំណង់ប្រាសាទមួយចំនួន។ ព្រះបាទជ័យវរ្ម័នទី២ បានកសាងគ្រឹះនយោបាយនៃការគ្រប់គ្រង និងដឹកនាំប្រទេស ដោយភ្ជាប់នូវជំនឿសាសនា និងដោយមានបង្កប់នូវវត្តមានទឹកនៅក្នុងនោះ ដើម្បីឱ្យប្រជានុរាស្ត្រអនុវត្តតាម។ ក្រោយមក ព្រះអង្គ ក៏បានយាងចុះពីភ្នំគូលេនត្រឡប់មករាជធានីហរៈហរិល័យវិញ រហូតដល់ ព្រះអង្គចូលទិវង្គត។

ជាការពិត ប្រព័ន្ធទឹកស្ទើរតែទាំងអស់ ដែលប្រៀបបីដូចជាសសៃឈាមនៃ

[១៤] វីដេអូឯកសារៈ ទឹកសាងអង្គរ https://fb.watch/fWK7FYiBXq/។

អង្គរមិនបានខូចខាតបាត់បង់ទៅណាឡើយ។ មួយពាន់ឆ្នាំហើយ ប្រព័ន្ធផ្លូវទឹកទាំងអស់នោះនៅតែផ្ដល់ផលប្រយោជន៍រហូតដល់សព្វថ្ងៃនេះ ក៏ប៉ុន្តែ ចូរកុំភ្លេចថា គេត្រូវស្ដារ ជួសជុល ថែទាំប្រព័ន្ធផ្លូវទឹកទាំងអស់នោះឡើងវិញដែរ។

## សេចក្ដីសន្និដ្ឋាន

ប្រទេសកម្ពុជាមានភូមិសាស្ត្រអំណោយផលពីធម្មជាតិ ដែលព័ទ្ធជុំវិញទៅដោយភ្នំនិងខ្ពង់រាប ជាហេតុធ្វើឱ្យកម្ពុជាសំបូរទៅដោយស្ទឹង ព្រែក បឹង និងទន្លេ ពិសេសត្រពាំង មានស្ទើរគ្រប់ភូមិ ឃុំ ស្រុក និងខេត្តទូទាំងប្រទេស។ ត្រពាំង ជាថ្លុកធំដែលកើតចេញពីមនុស្សជីក សម្រាប់ឱ្យដក់ទឹក ឬកើតចេញដោយកម្លាំងទឹកហូរច្រោះ។ ត្រពាំង ជាប្រភពទឹកដ៏សំខាន់សម្រាប់ថនិកសត្វ រុក្ខជាតិ និងមច្ឆជាតិ គ្រប់ប្រភេទ ដែលរស់នៅពឹងផ្អែកលើទឹកក្នុងត្រពាំង។

ដូនតាខ្មែរពិតជាមិនបានខ្ជីខ្ជាក្នុងការគិតគូរនូវប្រព័ន្ធទឹកទាំងឡាយ ដើម្បីកសាងអង្គរ ទ្រទ្រង់ប្រាសាទ ជីវភាពរស់នៅរបស់ប្រជារាស្ត្រ សត្វ និងរុក្ខជាតិឡើយ។ ការស្ដារត្រពាំង និងការជួសជុលនូវប្រព័ន្ធទឹកបុរាណឡើងវិញ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងលំហូរទឹកផង និងស្តុកទឹកសម្រាប់ប្រើប្រាស់ផង។

ព្រះមហាក្សត្រខ្មែរទ្រង់យល់ឃើញថា មិនត្រូវឱ្យតំណក់ទឹកណាមួយដែលហូរចុះពីភ្នំគូលែនទៅបឹងទន្លេសាបដោយមិនឆ្លងកាត់ការប្រើប្រាស់នោះទេ។ ហេតុដូច្នេះហើយបានជា ព្រះអង្គបញ្ជាឱ្យសង់បារាយណ៍ និងកសិន្ធុស្ដុកទឹកទុក ជាពិសេសក្នុងរដូវប្រាំងសម្រាប់ការស្រោចស្រព និងបំពេញទឹកក្រោមដីការពារគ្រឹះប្រាសាទ ប៉ុន្តែការដែលសំខាន់មួយទៀតនោះ គឺបារាយណ៍ និងកសិន្ធុទឹកទាំងនោះ ក៏មានមុខងារបញ្ចៀសទឹកជំនន់មិនឱ្យលិចក្រុង និងប្រាសាទផងដែរ។

ការបង្កើតទំនប់ឬក៏ទ្វារទឹកនានាដែលមានក្នុងប្រព័ន្ធទឹករបស់អង្គរ គឺសម្រាប់គ្រប់គ្រងលំហូរធំ បញ្ចៀសឬប្រមូលទឹកចូលមកក្នុងតំបន់អង្គរ ក្នុងពេលដែលមានទ្វារទឹកតូចៗសម្រាប់

បំពេញនៅក្នុងកសិន្ទុរបស់ប្រាសាទនៅក្នុងតម្រូវការរបស់ប្រាសាទ ដែលជាកសិន្ទុ និងជាគូទឹក ហើយទ្វារទឹកធំៗគឺសម្រាប់បញ្ចូលទៅបារាយណ៍ បញ្ចូនទៅស្ទឹងនានាដើម្បី ជួយការពារតំបន់ប្រាសាទអង្គរ។

រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអាជ្ញាធរមូលដ្ឋានឃុំ-សង្កាត់ត្រូវសហការរួមគ្នា ដើម្បីរៀបចំនូវគម្រោងក្នុងការស្តារនិងអភិរក្សប្រព័ន្ធទឹកឱ្យបានគង់វង្ស។

សរុបសេចក្តីប្រព័ន្ធស្តុកទឹកកម្ពុជាមានជាអាទិ៍ត្រពាំង ជាសម្បត្តិសាធារណៈ ទាំងអាជ្ញាធរ និងប្រជាពលរដ្ឋត្រូវចូលរួមថែរក្សាការពារ និងអភិវឌ្ឍន៍ឡើងវិញ ដើម្បីបង្ការគ្រោះរាំងស្ងួត ហួតហែងនារដូវប្រាំង ព្រមទាំងសម្រាប់ជាគុណប្រយោជន៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយប្រសិទ្ធភាព៕

## ឯកសារយោង


១) ឈឿន ប៊ុនធា *"ការស្តារនិងអភិវឌ្ឍត្រពាំងឡើងវិញ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម៖ករណីសិក្សាឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប"* គម្រោងស្រាវជ្រាវឆ្នាំ២០២២។

២) សឿន សោភ័ណ *"ការគ្រប់គ្រងសាធារណៈ"* ឆ្នាំ២០០៩-២០១០។

៣) ក្រសួងធនធានទឹកនិងឧត្តុនិយម *"ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក"* ឆ្នាំ២០០៧។

៤) ប្រកាស *"ច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម"* ឆ្នាំ១៩៩៣។

៥) អង្គការអភិរក្សអន្តរជាតិ *"បឹងទន្លេសាប៖ ការអភិរក្សប្រកពផលិតត្រីនៅកម្ពុជា"* ឆ្នាំ២០១៦។

៦) ក្រសួងព័ត៌មាន *"ត្រពាំងចំនួន១០ទីតាំងស្ថិតក្នុងដែនជម្រកសត្វព្រៃលំផាត់ស្តារចប់រួចរាល់"* ចេញផ្សាយឆ្នាំ២០២២។

៧) Administrative Change and Innovation: Chakrabarty, Bidyut and Mohit Bhattacharya (edit).2005: A Rrader. Oxford University Press New Delhi

៨) Water Management International Encyclopedia of Education (Fourth Edition), 2023

៩) https://thmeythmey.com/detail/85559

១០) https://www.iwmi.org